ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៤៤
ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩
សាលដីកា
លេខ ៧៤ VIII
ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០

# សាលដីកា
# តាងនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.លោក [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម (របាយការណ៍)

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ១៥២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ណាន ហៅ ណា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៣៤ ក្រV "វ" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន ៖

- **ជនជាប់ចោទ ៖**

១.ឈ្មោះ [redacted] ណាន ហៅ ណា ភេទស្រី អាយុ៣៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរនារីម៉ាស្សា ទីកន្លែងកំណើត [redacted] ខេត្តកំពង់ឆ្នាំង ទីលំនៅបច្ចុប្បន្នភូមិ [redacted]



Scanned with CamScanner

[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោះ [redacted] មានកូន ០២នាក់ ជាទីតិជន ទោសពីមុនគ្មាន ។ (អ្នកប្តឹងសាទុក្ខ)

-ឃុំខ្លួនថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ នៅពន្ធនាគារខេត្តកណ្តាល ។

-លោកស្រី [redacted] សុម៉ន ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ ៖ **ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់យីហោ សំណាងណាស់ បន្ទប់លេខ ១១ ស្ថិតនៅភូមិត្រពាំងសុក្រំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

២.ឈ្មោះ [redacted] សុខហ៊ីម ហៅ ឃីម ភេទស្រី អាយុ៣៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ អាជីវករទិញលក់ម៉ូតូ (យីហោសុខឃីម) មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) និងប្តីឈ្មោះ [redacted] មានកូន ០៥នាក់ ជាទីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ៖ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិគ្រួស សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារម៉េត ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] រាជធានីភ្នំពេញ ។

**អំពីអង្គហេតុ៖**

កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង ១៣ និង ១០ នាទីព្រឹក មានករណីឃាតកម្មគិតទុកជាមុន និង ទទួលផលចោរកម្ម កើតឡើងនៅចំណុចផ្ទះសំណាក់យីហោ សំណាងណាស់ បន្ទប់លេខ១១ ស្ថិតនៅភូមិត្រពាំងសុក្រំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល និងចំណុចភូមិគ្រួស សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ បង្កឡើងដោយឈ្មោះ [redacted] ណាន ហៅ ណា ភេទស្រី អាយុ ៣៣ឆ្នាំ (ឃាតកម្មគិតទុកជាមុន) និងឈ្មោះ [redacted] សុខហ៊ីម ភេទស្រី អាយុ៣៧ឆ្នាំ (ទទួលផលចោរកម្ម) ដោយឈ្មោះ [redacted] ណាន ហៅ ណា ត្រូវការប្រាក់ចំនួន ២.៥០០ ដុល្លារអាមេរិក ទៅដោះស្រាយប្តីដែលជាប់ពីបទល្មើសគ្រឿងញៀននៅពន្ធនាគារព្រៃស ហើយជនសង្ស័យសង្កេតឃើញជនរងគ្រោះឈ្មោះ [redacted] សុភាព មានគ្រឿងអលង្ការជាប់នឹងខ្លួនច្រើន ក៏បែកគំនិតណាត់ជនរងគ្រោះបបួលទៅផ្ទះសំណាក់រួមភេទ ។ ឈ្មោះ [redacted] ណាន ហៅ ណា បានយកកាំបិតចុងស្រួចដាក់តាមខ្លួនទៅជាមួយផងដែរ ។ ពេលជនរងគ្រោះចូលបន្ទប់ទឹក ឈ្មោះ [redacted] ណាន ហៅ ណា បានយកកាំបិតទៅដាក់នៅខាងក្រោមខ្នើយរួចជាស្រេច ហើយខណៈពេលជនរងគ្រោះមិនចាប់អារម្មណ៍ ពេលរួមភេទ ឈ្មោះ [redacted] ណាន បានដកកាំបិតពីក្រោមខ្នើយមកចាក់លើជនរងគ្រោះចំនួន ១៨កាំបិត បណ្តាលឱ្យស្លាប់ភ្លាមៗ ។ ក្រោយពីសម្លាប់ជនរងគ្រោះរួច ឈ្មោះ [redacted] ណាន ហៅ ណា បានប្រមូលទ្រព្យសម្បត្តិជនរងគ្រោះមាន ចិញ្ចៀន ខ្សែក ទូរស័ព្ទ យកទៅលក់នៅផ្សារជម្ពូវ័ន រីឯម៉ូតូបានយកទៅលក់នៅចំណុចភូមិគ្រួស សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលមាន



Scanned with CamScanner

ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) ប្ដីឈ្មោះ [redacted] មានកូន ០២នាក់ ជាទីតិជន ទោសពីមុនគ្មាន ។ (អ្នកប្ដឹងសាទុក្ខ)

-ឃុំខ្លួនថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ នៅពន្ធនាគារខេត្តកណ្ដាល ។

-លោកស្រី [redacted] សុម៉ន ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ ៖ **ឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់យីហោ សំណាងណាស់ បន្ទប់លេខ ១១ ស្ថិតនៅភូមិត្រពាំងសុក្រំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

២.ឈ្មោះ [redacted] សុខហ៊ីម ហៅ ឃីម ភេទស្រី អាយុ៣៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ អាជីវករទិញលក់ម៉ូតូ (យីហោសុខឃីម) មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រស់) ម្ដាយឈ្មោះ [redacted] (រស់) និងប្ដីឈ្មោះ [redacted] មានកូន ០៥នាក់ ជាទីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ៖ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅភូមិគ្រួស សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារ៉េត ភេទស្រី អាយុ៦២ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] រាជធានីភ្នំពេញ ។

### អំពីអង្គហេតុ ៖

កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង ១៣ និង ១០ នាទីព្រឹក មានករណីឃាតកម្មគិតទុកជាមុន និង ទទួលផលចោរកម្ម កើតឡើងនៅចំណុចផ្ទះសំណាក់យីហោ សំណាងណាស់ បន្ទប់លេខ១១ ស្ថិតនៅភូមិត្រពាំងសុក្រំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល និងចំណុចភូមិគ្រួស សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ បង្កឡើងដោយឈ្មោះ [redacted] ណាន ហៅ ណា ភេទស្រី អាយុ ៣៣ឆ្នាំ (ឃាតកម្មគិតទុកជាមុន) និងឈ្មោះ [redacted] សុខហ៊ីម ភេទស្រី អាយុ៣៧ឆ្នាំ (ទទួលផលចោរកម្ម) ដោយឈ្មោះ [redacted] ណាន ហៅ ណា ត្រូវការប្រាក់ចំនួន ២.៥០០ ដុល្លារអាមេរិក ទៅដោះស្រាយប្ដីដែលជាប់ពីបទល្មើសគ្រឿងញៀននៅពន្ធនាគារព្រៃស ហើយជនសង្ស័យសង្កេតឃើញជនរងគ្រោះឈ្មោះ [redacted] សុភាព មានគ្រឿងអលង្ការជាប់នឹងខ្លួនច្រើន ក៏បែកគំនិតណាត់ជនរងគ្រោះបបួលទៅផ្ទះសំណាក់រួមភេទ ។ ឈ្មោះ [redacted] ណាន ហៅ ណា បានយកកាំបិតចុងស្រួចដាក់តាមខ្លួនទៅជាមួយផងដែរ ។ ពេលជនរងគ្រោះចូលបន្ទប់ទឹក ឈ្មោះ [redacted] ណាន ហៅ ណា បានយកកាំបិតទៅដាក់នៅខាងក្រោមខ្នើយរួចជាស្រេច ហើយខណៈពេលជនរងគ្រោះមិនចាប់អារម្មណ៍ ពេលរួមភេទ ឈ្មោះ [redacted] ណាន បានដកកាំបិតពីក្រោមខ្នើយមកចាក់លើជនរងគ្រោះចំនួន ១៨កាំបិត បណ្ដាលឱ្យស្លាប់ភ្លាមៗ ។ ក្រោយពីសម្លាប់ជនរងគ្រោះរួច ឈ្មោះ [redacted] ណាន ហៅ ណា បានប្រមូលទ្រព្យសម្បត្តិជនរងគ្រោះមាន ចិញ្ចៀន ខ្សែក ទូរស័ព្ទ យកទៅលក់នៅផ្សារជម្ពូវ័ន រីឯម៉ូតូបានយកទៅលក់នៅចំណុចភូមិគ្រួស សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលមាន



Scanned with CamScanner

ម្ចាស់ហាងឈ្មោះ [redacted] សុខហ៊ីម ។ ការទិញលក់នេះគឺមិនមានឯកសាររបស់ម្ចាស់ម៉ូតូផ្ទាល់ឡើយ ហើយឈ្មោះ [redacted] សុខហ៊ីម នៅតែបានទទួលទិញលក់ ហើយបានយកទៅលក់បន្តភ្លាមៗទៅឱ្យអ្នកនៅខេត្តកំពង់ចាមមិនស្គាល់ឈ្មោះ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១០៤ "ឈ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូង ខេត្តកណ្តាល ដែលមានខ្លឹមសារដូចតទៅ៖

១.ឱ្យឈ្មោះ [redacted] សុខហ៊ីម ហៅ ឃីម ភេទស្រី អាយុ៣៧ឆ្នាំ រួចខ្លួនពីបទ៖ ទទួលផលចោរកម្ម ប្រព្រឹត្តនៅភូមិគ្រួស សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ យោងតាមមាត្រា ៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ណាន ហៅ ណា ភេទស្រី អាយុ៣៣ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ៣០ (សាមសិប) ឆ្នាំ ពីបទ៖ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ឃីហោ សំណាងណាស់ បន្ទប់លេខ ១១ ស្ថិតនៅភូមិត្រពាំងស្វាយ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

៣.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ណាន សងសំណងទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាម៉េត ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល។

៤. វត្ថុតាងមាន៖

-កាំបិតចុងស្រួចចំនួន ០១ ប្រវែង ២៤ សង់ទីម៉ែត្រ (ផ្លែប្រវែង ១៤ សម និងទទឹង ២,៥ សម) ស្បែកជើងសកចំនួន ០១គូរ ពណ៌សូកូឡា អាវយឺតដៃវែងក្រឡាបង្កង់ ពណ៌ស ទឹកប៊ិច និងត្រួយចេក (អាវស៊ិកមានឡេវបី) ខោជើងវែងពណ៌ត្រែអី និងខ្សែក្រវ៉ាត់ទាហាន អាវយឺតរៀលត្លៀកពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅចំនួន ០១គូរ (ស្រី) មួកសុវត្ថិភាពចំនួន ០១ ពណ៌ខ្មៅ ម៉ាក Honda កំរាលជូតជើងចំនួន ០១ មានដានជើងប្រឡាក់ឈាម ជ្រក់ជើងមាន់ចំនួន ០១ស្បោង ដបទឹកសុទ្ធចំនួន ០២ (មានទឹក) ស្រោមអនាម័យចំនួន ០២ (ពីរ) សាប៊ូដុសខ្លួនចំនួន ០២ដុំ (តូច) ច្រាសដុសធ្មេញចំនួន ០២ (ពីរ) វ៉ែនតាដងខ្មៅចំនួន ០១ (មួយ) និងសក់មួយសរសៃប្រឡាក់ឈាម ត្រូវរឹបអូសបំផ្លាញចោល។

-ទូរស័ព្ទដៃចំនួន ០២គ្រឿង ម៉ាកអាយហ្វូន៦ ពណ៌ស លាយទឹកមាស និងម៉ាកសាំសុង កាឡាស៊ីអានសេរីនពណ៌ទឹកមាស នាឡិកាចំនួន ០១ ពណ៌មាស ម៉ាក KING ខ្សែចង្កេះចំនួន ០១ ខ្សែ ជាលោហធាតុពណ៌ស អាកូម (ID) ចំនួន ០១ (មួយ) ពណ៌ខ្មៅ លោហៈធាតុពណ៌ទង់ដែង ចំនួន ០១ ខ្សែ (ខ្សែក) លោហៈធាតុពណ៌លឿងចំនួន ១៤ ដប់បួនកង (ប្រភេទកងដៃ) លោហៈ ធាតុពណ៌លឿងចំនួន ០២ វង់ (ប្រភេទចិញ្ចៀន) លោហៈធាតុពណ៌លឿងចំនួន ០១ ខ្សែ (ប្រភេទខ្សែក) លោហៈធាតុពណ៌លឿងចំនួន ០២ ខ្សែ (ប្រភេទខ្សែជើង) លោហៈធាតុពណ៌លឿងចំនួន ០១ ខ្សែ (ប្រភេទខ្សែដៃ) លោហៈធាតុពណ៌សចំនួន ០១ ខ្សែ (ប្រភេទខ្សែចង្កេះ) កាបូបស្ពាយ ពណ៌ខ្មៅចំនួន ០១ សំបុត្រលក់ទិញគ្រឿងអលង្ការចំនួន ០២ សន្លឹក និងសៀវភៅទិញលក់ម៉ូតូ ចំនួន ០២ក្បាល ត្រូវរឹបអូស។



Scanned with CamScanner

៥.សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ នៅចំពោះមុខជនជាប់ចោទទាំងពីរនាក់ និងកំបាំងដើមបណ្តឹងរដ្ឋប្បវេណី។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted]ណាន ហៅ ណា ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១០៤ "ឈ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌ ៣៤ ក្រV "វ" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ របស់ពិរុទ្ធជនឈ្មោះ [redacted]ណាន ហៅ ណា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០៤ (ឈ) ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល។

៣.បន្តឃុំខ្លួនពិរុទ្ធជនឈ្មោះ [redacted]ណាន ហៅ ណា តាមនីតិវិធីច្បាប់។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ ចំពោះមុខពិរុទ្ធជនឈ្មោះ [redacted] ណាន ហៅ ណា និងមេធាវីការពារសិទ្ធិ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៩ ។

បើកប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៥២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted]ណាន ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៣៤ ក្រV "វ" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលធ្វើសេចក្តីសន្និដ្ឋានសុំថា៖

-យល់ឃើញថា ជនជាប់ចោទ បានទទួលសារភាពហើយ ហើយតុលាការអង្គហេតុក៏បានសម្រាលទោសត្រឹម ៣០ឆ្នាំ ហើយដែរ ។

តំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឱ្យ៖

១-បណ្តឹងសាទុក្ខលេខ ១៥២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted]ណាន ហៅ ណា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសទៅនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៣៤ ក្រV "វ" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។



Scanned with CamScanner

+លោកស្រី [redacted] សាម៉េត ជាដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយថា៖ សុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទ ព្រមទាំងសងសំណងរដ្ឋប្បវេណីមកឱ្យខ្ញុំ ។

+លោកស្រី [redacted] សុវ៉ន ជាមេធាវីការពារឱ្យជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្រោយពីបានសិក្សាលើសំណុំរឿងរួចមកឃើញថា ពិតជាមានករណីឃាតកម្មគិតទុកជាមុនពិតមែន ។ ជនជាប់ចោទបានណាត់ជនរងគ្រោះទៅរួមភេទជាមួយគ្នា ដោយមានគំនិតចង់បានប្រាក់ពីជនរងគ្រោះ ដោយចាញ់បោកពាក្យគេថា បើមានលុយចំនួន ២.០០០$ អាចឱ្យប្ដីរួចពីក្នុងពន្ធនាគារ ។ ជនជាប់ចោទពុំមានអ្នកណាមើលថែទាំកូន ព្រោះថាខ្លួន និងប្ដីជាប់ពន្ធនាគារទាំង០២នាក់ កូនក្ដីខ្ញុំបានទទួលស្គាល់នូវទោសកំហុសរបស់ខ្លួន ហើយប្ដឹងសាទុក្ខមកនេះគឺដើម្បីស្នើសុំឱ្យតុលាការកំពូលជួយបន្ធូរបន្ថយទោសដល់ខ្លួន ។

សំណូមពរ សូមឱ្យតុលាការផ្ដន្ទាទោសត្រឹមតែ ១៥ឆ្នាំ បានហើយ ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារក្ដី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ១៥២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ណាន ហៅ ណា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ការដែលមេធាវីការពារជនជាប់ចោទ បានធ្វើសេចក្ដីសន្និដ្ឋាននាពេលសវនាការនេះថា កូនក្ដីខ្លួនជាជនជាប់ចោទឈ្មោះ [redacted] ណាន បានទទួលស្គាល់កំហុសតាមការប្រកាសទោសរបស់តុលាការថ្នាក់ក្រោមហើយ ប៉ុន្តែការប្ដឹងសាទុក្ខមកនេះ ដើម្បីសុំឱ្យតុលាការកំពូលជួយបន្ធូរបន្ថយទោសបន្ថែមទៀតនោះ តុលាការកំពូលមិនអាចពិចារណាបានទេ ព្រោះថា តាមបញ្ញត្តិមាត្រា ៤១៩ (មូលហេតុនៃបណ្ដឹងសាទុក្ខ), ៤៣៦ (សេចក្ដីសម្រេចលើបញ្ហាគតិយុត្ត) និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលពិចារណាតែលើអង្គច្បាប់ ឯពាក់ព័ន្ធនឹងការសម្រាលទោស គឺជាសមត្ថកិច្ចរបស់តុលាការអង្គហេតុ ។ ម្យ៉ាងវិញទៀត តាមមាត្រា ២០០ (បទឃាតកម្មគិតទុកជាមុន) នៃក្រមព្រហ្មទណ្ឌ មានទោសពន្ធនាគារអស់មួយជីវិត តែរឿងនេះ តុលាការអង្គហេតុ បានប្រកាសទោសក្នុងកម្រិត៣០ឆ្នាំ ដែលស្ថិតក្នុងស្ថានសម្រាលទោសពិសេសហើយ ។

៣-យល់ឃើញថា តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និដ្ឋានថា រឿងក្ដីនេះមានភស្តុតាងដាក់បន្ទុកធ្ងន់ធ្ងរ និងទោសដែលតុលាការអង្គហេតុបានប្រកាសស្មើនឹង៣០ឆ្នាំ ហេតុនេះស្នើសុំតម្កល់



Scanned with CamScanner

សាលដីការបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ។ រីឯភាគីដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំមកតុលាការកំពូលជួយរកយុត្តិធម៌ឱ្យភាគីខ្លួនផង ។ ករណីទាំងនេះ តុលាការកំពូលបានពិចារណា ដូចមានក្នុងសំអាងហេតុខាងលើនេះ ។

៤-យល់ឃើញថា សាលដីកាលេខ ៣៤ ក្រV "វ" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## សម្រេច

១-បដិសេធបណ្តឹងសាទុក្ខលេខ ១៥២ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៩ របស់ឈ្មោះ [redacted] ណាន ហៅ ណា ។

២-តម្កល់សាលដីកាលេខ ៣៤ ក្រV "វ" ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០។

Scanned with CamScanner